**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខៈ..៣១០៥......កប/ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩

# ប្រកាស
## ស្តីពី
## ការងារនេសាទសមុទ្រ

## រដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## <u>សម្រេច</u>

**ប្រការ ១.-** និយោជកនៃទូកនេសាទសមុទ្រទាំងអស់ ដែលស្ថិតក្នុងដែនអនុវត្តនៃមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់ដល់កម្មករនិយោជិតរបស់ខ្លួន លើលក្ខខណ្ឌការងារមានសុវត្ថិភាព និងមានជីវភាពរស់នៅដ៏សមរម្យមានអនាម័យត្រឹមត្រូវ។

**ប្រការ ២.- សម្លៀកបំពាក់ការងារ**

និយោជកត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្លៀកបំពាក់ពីរសម្រាប់ក្នុង១រដូវ /ឆ្នាំ។ សម្រាប់ទី១ ត្រូវផ្តល់ឱ្យនៅពេល ១៥ថ្ងៃ ក្រោយពីកម្មករនិយោជិតនោះបានចូលធ្វើការដំបូង។ សម្លៀកបំពាក់ មួយសម្រាប់ៗត្រូវមាន២ផ្នែកយ៉ាងតិច គឺសំពត់ឬខោ ហើយនិងអាវដែលមានទំហំស្របនឹង HS

អាសយដ្ឋានអគារលេខ ៣. មហាវិថីសហព័ន្ធរុស្ស៊ី. សង្កាត់ទឹកល្អក់២. ខ័ណ្ឌទួលគោក.ប្រអប់សំបុត្រ P.O Box 1506ទូរស័ព្ទ និង ទូរសារៈ (០២៣) ៣៥៣ ៥៣៨

ខ្លួនប្រាណ ព្រមទាំងសកម្មភាពការងាររបស់កម្មករ និយោជិត ។ និយោជកត្រូវផ្តល់មធ្យោបាយសម្រាប់ថែទាំសម្លៀកបំពាក់ទាំងនោះ ដូចជាសាប៊ូ ជាដើម ។

បទបញ្ជាផ្ទៃក្នុង អាចកំណត់ពីលក្ខខណ្ឌដែលសម្លៀកបំពាក់នេះត្រូវបែងចែក ប្រើប្រាស់ និងថែទាំ ។

**ប្រការ ៣.- សម្ភារៈការពារបុគ្គល**

និយោជក ត្រូវផ្តល់ឱ្យដោយឥតគិតថ្លៃ ដល់កម្មករនិយោជិតម្នាក់ៗ នូវសម្ភារៈការពារបុគ្គលជាចាំបាច់ ដូចជា អាវពោងមានចំណាំងផ្លាត និងកញ្ចែ អាវអៀមកៅស៊ូ អាវភ្លៀងនៅរដូវភ្លៀង ឬមួកហាមធំជាដើម ។ល។ និយោជក៏ត្រូវគិតគូរផងដែរ ឱ្យមានសម្ភារៈវិទ្យុទាក់ទងសម្រាប់ប្រើប្រាស់នៅពេលចាំបាច់ ។

**ប្រការ ៤.- ភេសជ្ជៈអនាម័យ**

និយោជកនៃទូកនេសាទសមុទ្រទាំងអស់ ត្រូវផ្តល់ភេសជ្ជៈអនាម័យឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិតរបស់ខ្លួនស្របទៅតាមប្រកាសលេខ ០៥៤ ស.ក.ប.យ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ ។

**ប្រការ ៥.- ការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម**

ការលើកដាក់ទម្ងន់ផ្សេងៗ ជាពិសេស សម្រាប់កុមារអាយុក្រោម១៨ឆ្នាំ ត្រូវអនុវត្តឱ្យបានស្របទៅតាមប្រកាសលេខ ១២៤ ស.ក.ប.យ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម ។

**ប្រការ ៦.- ការងារកុមារអាយុក្រោម១៨ឆ្នាំ**

កុមារអាយុក្រោម១៥ឆ្នាំ មិនអនុញ្ញាតឱ្យចុះទូកទៅនេសាទដាច់ខាត ។ ចំពោះកុមារអាយុលើសពី១៥ឆ្នាំ ទៅក្រោម១៨ឆ្នាំ អាចអនុញ្ញាតឱ្យទៅចូលរួមធ្វើការនេសាទបាន តែក្នុងលក្ខខណ្ឌធ្វើតែការងារនៅលើទូកនេសាទប៉ុណ្ណោះមិន អនុញ្ញាតឱ្យចុះទឹក ឬមុជចុះក្នុងទឹកឡើយ ។

**ប្រការ៧.- សេវាសុខភាព**

និយោជកនៃទូកនេសាទសមុទ្រ ត្រូវរៀបចំឱ្យមានសេវាសុខភាពសម្រាប់កម្មករ និយោជិតរបស់ខ្លួន ស្របនឹងប្រកាសរួមលេខ ៣៣០ ស.ក.ប.យ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស និងប្រកាសរួមលេខ ១៣៩ ស.ក.ប.យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១ ស្តីពីលក្ខខណ្ឌ និងបេសកកម្ម សេវាពេទ្យសហគ្រាស ។

**ប្រការ ៨.-** ការមិនអនុវត្តន៍តាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ ស្តីពីការងារ ។

**ប្រការ ៩.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តន៍ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន**
- គ្រប់ក្រសួងពាក់ព័ន្ធ **"ដើម្បីជូនជ្រាប"**
- អគ្គនាយកដ្ឋានការងារ
- អគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង **"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"**
- សមាគមនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា **"ដើម្បីអនុវត្ត"**
- សហព័ន្ធសហជីព **"ដើម្បីជូនជ្រាប"**
- គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ **"ដើម្បីជួយផ្សព្វផ្សាយ"**
- កាលប្បវត្តិ និងឯកសារ

**រដ្ឋមន្ត្រី**

**វង្ស សុត**